# *អាយ៉ៃ*

*ទម្រង់អាយ៉ៃ យកតាមឈ្មោះអ្នកច្រៀង "**ពូយ៉ៃ**" ហើយមានដើមកំណើតពីចម្រៀងប្របកែ ដែលជាចម្រៀងឆ្លើយឆ្លងគ្នារវាងស្រីម្នាង និងប្រុសម្នាង ឈរតម្រៀបជាជួរទល់មុខគ្នា ហើយទះដៃព្រមៗគ្នាជាចង្វាក់។ អ្នកច្រៀងស្រីប្រុសទាំងសងខាង ច្រៀងឆ្លើយឆ្លងតគ្នាទៅវិញទៅមក ជាពិសេសនៅពេលលេងល្បែងប្រជាប្រិយចោលឈូងនៅក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់ខ្មែរយើង។*

*ទៅតាមពេលវេលា ចម្រៀងប្របកែក៏មានការវិវត្តដោយសិល្បករសិល្បការិនីដែលមានទេពកោសល្យបានច្នៃប្រឌិតឱ្យក្លាយទៅជាចម្រៀងច្រៀងឆ្លើយឆ្លងគ្នារវាងស្រី និងប្រុសកំដរដោយតន្ត្រីវង់ធំ ដែលមានឧបករណ៍ទ្រខ្មែរ ឬទ្រខ្សែ៣ ចាប៉ីដងវែង ទ្រសោ ទ្រអ៊ូ ក្រពើ (តខេ) ខ្លុយ ប៉ីប្របុស ស្គរដៃ និងក្រាប់។ល។*

*តាមឯកសារស្រាវជ្រាវ និងលោកសាស្ត្រាចារ្យព្រឹទ្ធាចារ្យ ម៉េង ហ៊ុន (ត្រូវជាស្វាមីរបស់អ្នកស្រី សង្វារពេជ្រ សិល្បការិនីចម្រៀងអាយ៉ៃដ៏ល្បីនាមុនសម័យខ្មែរក្រហម និងជាលោកឪពុក និងអ្នកម្តាយរបស់អ្នកនាង ម៉េង កែវពេជ្ជតា) ជាបរមគ្រូនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងជាតន្ត្រីករដ៏ចំណានល្បីល្បាញនៅប្រទេសកម្ពុជាប្រកបដោយទេពកោសល្យខ្ពស់ នាមុន និងក្រោយសម័យខ្មែរក្រហម លោកមានប្រសាសន៍ថា ទម្រង់អាយ៉ៃ កើតចេញមកពី តន្ត្រីប្របកែ ដែលមាននៅប្រទេសកម្ពុជាយើងជាយូរយារណាស់មកហើយ។ មកដល់អំឡុងចុង សតវត្សទី១៩ ឬដើមសតវត្សទី២០ ទើប «ពូយ៉ៃ» (១៨៧៨-១៩៥៨) ដែលមានដើម កំណើតនៅភូមិឈើនាងខ្ពស់ ឃុំព្រះពុទ្ធនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលជាសមាជិក សម្តែងនៅក្នុងតន្ត្រីវង់ធំមួយក្រុមនៅភូមិត្រពាំងទា ឃុំពងទឹក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានធ្វើឱ្យមានព្រឹត្តិការណ៍ថ្មី សម្រាប់ទម្រង់សិល្បៈនេះ[១]។*

*ដោយសារការប៉ិនប្រសប់របស់ពូយ៉ៃ ដែលជាអ្នកចម្រៀងដ៏ពូកែកាព្យឃ្លោងសំឡេងក៏ពីរោះ ពោរពេញទៅដោយសំនួនវោហារចោទឆ្លើយលែបខាយដោយឥតព្រាងទុក ចេះរាំ និងចេះសម្តែង កំប្លុកកំប្លែង ថែមទាំងចេះក្បាច់គុនផងនោះ បានធ្វើឱ្យទស្សនិកជនទូទៅ*

---

*[១] ពេជ្រ ទុំក្រវិល ២០០០: ៤០*

ចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើរូបគាត់ រហូតដល់ក្រោយៗមក ពេលដែលគេទៅមើលសិល្បៈតន្ត្រីវង់ធំ ដែលមានពូយ៉ៃជាសមាជិកនោះ គេក៏តែងនិយាយថា៖ "ទៅមើលពូយ៉ៃ" ឬ "ទៅមើលតាយ៉ៃ" តៗមក។

នាពេលបច្ចុប្បន្ន វង់តន្ត្រីអាយ៉ៃ មានអ្នកច្រៀងស្រីម្នាក់ និងប្រុសម្នាក់ ច្រៀងឆ្លើយឆ្លងគ្នា ចោទឆ្លើយ ផ្ទៃផ្កា ដោយរៀបហារឥតព្រាងទុកបង្កប់នូវពាក្យផ្ដោះផ្ដងបញ្ចិតបញ្ចៀងក្នុងអត្ថន័យស្នេហា កំដរដោយវង់តន្ត្រីដែលមានឧបករណ៍ទ្រសោ ទ្រអ៊ូ ឃឹម ក្រពើ ខ្លុយ ស្គរដៃ និងឈឹងធ្វើឱ្យទស្សនិកជនសើចក្អាកក្អាយសប្បាយរីករាយ។

ទម្រង់ ឬសិល្បៈអាយ៉ៃ មានពីរប្រភេទ៖ អាយ៉ៃឆ្លងឆ្លើយ និងអាយ៉ៃរឿង។ អាយ៉ៃឆ្លងឆ្លើយសម្ដែងឡើងដោយអ្នកច្រៀងស្រីម្នាក់ និងប្រុសម្នាក់ ច្រៀងឆ្លងឆ្លើយគ្នាលែបខាយដោយរៀបហារឥតព្រាងទុកនៅលើគំនិត ឬប្រធានបទអ្វីមួយ។ ឯអាយ៉ៃរឿងវិញ គឺអ្នកច្រៀងទាំងពីរនាក់ច្រៀងរៀបរាប់ហូរហែបកស្រាយពីរឿងអ្វីមួយ។ លោក ពេជ្រ ទុំក្រវិល ហៅប្រភេទសិល្បៈនេះថា "**ល្ខោនធ្វើពើ**"[២]។ យើងគួរកត់សម្គាល់ផងដែរថា ដោយយោងទៅតាម អនុសាសន៍របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា ក្រោមចក្ខុវិស័យនិងគោលដៅថែរក្សានិងបណ្ដុះបណ្ដាលសិល្បៈវប្បធម៌ខ្មែរឲ្យគង់វង្ស និងរីកដុះដាល មហាវិទ្យាល័យតូរ្យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានបញ្ចូលមុខវិជ្ជា សិល្បៈអាយ៉ៃ ទៅក្នុងកម្មវិធីសិក្សារបស់មហាវិទ្យាល័យនៅឆ្នាំ២០០០ ជារៀងរហូតមក។

## ឯកសារយោង

ពេជ្រ, ទុំក្រវិល

២០០០. *ស្បែកពណ៌និងស្បែកតូច*. ភ្នំពេញ: មូលនិធិ តូយ៉ូតា។

ពេជ្រ ទុំក្រវិល

២០០៣. *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

[២] ពេជ្រ ទុំក្រវិល ២០០៣: ២១២





អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង